| ៣៩០- | លោកស្រី | សួន ចំបាន | គ្រូបង្រៀនសាលាបឋមសិក្សាសណ្តាន់ ស្រុកអង្គរធំ |
| ៣៩១- | លោកស្រី | ចយ ធារ៉ា | គ្រូបង្រៀនសាលាបឋមសិក្សាខ្ទីង ស្រុកអង្គរធំ |
| ៣៩២- | លោក | យឿន ចិត្រ | គ្រូបង្រៀនសាលាបឋមសិក្សាពាក់ស្នែង ស្រុកអង្គរធំ |
| ៣៩៣- | លោក | ឆាយ ពៅ | គ្រូបង្រៀនសាលាបឋមសិក្សាពាក់ស្នែង ស្រុកអង្គរធំ |

| | | | |
|---|---|---|---|
| ៣៩៤- | លោកស្រី | ស្ដើង ធិប | គ្រូបង្រៀនសាលាបឋមសិក្សាពាក់ស្នែង ស្រុកអង្គរធំ |
| ៣៩៥- | លោក | វ៉ាត សារ៉េត | គ្រូបង្រៀនវិទ្យាល័យរុនតាឯក ស្រុកបន្ទាយស្រី |
| ៣៩៦- | លោកស្រី | ព្រាន សុឌឹម | គ្រូបង្រៀនសាលាបឋមសិក្សាប្រិយ៍ ស្រុកបន្ទាយស្រី |
| ៣៩៧- | លោកស្រី | ហិប ស្រីស្រស់ | គ្រូបង្រៀនសាលាបឋមសិក្សាតាឯក ស្រុកបន្ទាយស្រី |
| ៣៩៨- | លោកស្រី | ចឹង អឹង | គ្រូបង្រៀនសាលាបឋមសិក្សាបន្ទាយសំរែ ស្រុកបន្ទាយស្រី |
| ៣៩៩- | លោក | សូត្រ ស៊ី | គ្រូបង្រៀនសាលាបឋមសិក្សាកំព្រំ ស្រុកបន្ទាយស្រី |
| ៤០០- | លោកស្រី | យ៉ែម ប៉ុក | គ្រូបង្រៀនសាលាបឋមសិក្សាគូលែនថ្មី ស្រុកបន្ទាយស្រី |
| ៤០១- | លោកស្រី | កឿង សាវ៉ាន់ | គ្រូបង្រៀនសាលាបឋមសិក្សាជាលាធំ ស្រុកបន្ទាយស្រី |
| ៤០២- | លោកស្រី | កយ តួត | គ្រូបង្រៀនសាលាបឋមសិក្សាតាកុ ស្រុកបន្ទាយស្រី |
| ៤០៣- | លោកស្រី | ញឹម ចាន់ធូ | គ្រូបង្រៀនសាលាបឋមសិក្សាវត្តរុន ស្រុកបន្ទាយស្រី |
| ៤០៤- | លោកស្រី | ព្រំ ចារឹត | គ្រូបង្រៀនសាលាបឋមសិក្សាតាទុំ ស្រុកបន្ទាយស្រី |
| ៤០៥- | លោក | នី ប្រាវុឌ្ឍ | គ្រូបង្រៀនវិទ្យាល័យស្រុកស្វាយលើ ស្រុកស្វាយលើ |
| ៤០៦- | លោកស្រី | ឡុង ផល្លីន | គ្រូបង្រៀនវិទ្យាល័យស្រុកស្វាយលើ ស្រុកស្វាយលើ |
| ៤០៧- | លោកស្រី | គុត គីម | គ្រូបង្រៀនសាលាបឋមសិក្សារលំទូក ស្រុកស្វាយលើ |
| ៤០៨- | លោកស្រី | លី តុលា | គ្រូបង្រៀនសាលាបឋមសិក្សារលំទូក ស្រុកស្វាយលើ |
| ៤០៩- | លោកស្រី | រឿន ពៅ | គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន ខ្នាក្រៅ ស្រុកស្វាយលើ |

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១០កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៤០ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការចំពោះកិច្ចរៀបចំការប្រកួតកីឡាយុទ្ធគុនចម្រុះខ្មែរបុរាណ "ពានរង្វាន់សម្តេចធិបតី"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត **គណៈកម្មការចំពោះកិច្ចរៀបចំការប្រកួតកីឡាយុទ្ធគុនចម្រុះខ្មែរបុរាណ "ពានរង្វាន់សម្តេចធិបតី"** ដែលសរសេរជាអក្សរកាត់ថា **គ.ច.យ.ខ.ព.**។

**ប្រការ២.-**

**គ.ច.យ.ខ.ព.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត **ថោង ខុន** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | ប្រធាន |
| ២. ឯកឧត្តម **នេត្រ ភក្ត្រា** | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | អនុប្រធាន |
| ៣. ឯកឧត្តម **ជា ម៉ូរ៉ា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៤. ឯកឧត្តម **រ័ត្ន សណ្តាប់** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៥. ឯកឧត្តម **វ៉ាត់ ចំរើន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានសហព័ន្ធកីឡាយុទ្ធគុនចម្រុះកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |

| | | |
|---|---|---|
| ៦. ឯកឧត្តម **ម៉ុក ច័ន្ទសុធា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតី | អនុប្រធាន |
| ៧. ឯកឧត្តមបណ្ឌិត **ម៉ឹង មករា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៨. ឯកឧត្តម **ហ៊ឹម យ៉ាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៩. ឯកឧត្តម **គង់ ធីរៈ** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ១០. ឯកឧត្តម **វ៉ា ស៊ិនតីរម្យ** | | សមាជិក |
| ១១. ឯកឧត្តម **ពេជ អឡ** | | សមាជិក |
| ១២. ឯកឧត្តម **តែម ម៉ឺន** | | សមាជិក |
| ១៣. ឯកឧត្តម **ប៉ុន សុខ** | | សមាជិក |
| ១៤. ឧត្តមសេនីយ៍ទោ **ខូច ឆាយ** | | សមាជិក |
| ១៥. ឧត្តមសេនីយ៍ត្រី **មាស សុភារិទ្ធ** | | សមាជិក |
| ១៦. ឧកញ៉ា **ស្រី ចាន់ថន** | | សមាជិក |
| ១៧. បណ្ឌិត **សេខ ប៊ុនសុខ** | | សមាជិក |
| ១៨. ឯកឧត្តម **គីម មិនា** | | សមាជិក |
| ១៩. ឯកឧត្តម **ប៊ុយ សុភ័ណ្ឌា** | | សមាជិក |
| ២០. ឯកឧត្តម **គង់ សូលីដា** | | សមាជិក |
| ២១. ឯកឧត្តម **ណាយ ផាណា** | | សមាជិក |
| ២២. ឯកឧត្តម **ចោង ធន** | | សមាជិក |
| ២៣. ឯកឧត្តម **អ៊ុក ហៃសីឡា** | | សមាជិក |
| ២៤. លោកសាស្ត្រាចារ្យ **ខ្លូត រតនា** | | សមាជិក |
| ២៥. លោក **ចោង និស្ស័យទេព** | | សមាជិក។ |

ការតែងតាំង និងផ្លាស់ប្តូរសមាសភាព **គ.ច.យ.ខ.ព.** ត្រូវធ្វើឡើងតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមការស្នើសុំរបស់ប្រធាន **គ.ច.យ.ខ.ព.** ។

**ប្រការ៣.-**

**គ.ច.យ.ខ.ព.** មានអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ជាអនុប្រធាន ដើម្បីទទួលធ្វើជាម្ចាស់ផ្ទះក្នុងករណីមានការប្រកួតកីឡាយុទ្ធគុនចម្រុះខ្មែរបុរាណ "ពានរង្វាន់សម្តេចធិបតី" នៅតាមបណ្តារាជធានី-ខេត្តនីមួយៗ ។

**ប្រការ៤.-**

**គ.ច.យ.ខ.ព.** មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងអនុម័តលើផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពក្នុងដំណើរការប្រកួតកីឡាយុទ្ធគុនចម្រុះខ្មែរបុរាណ "ពានរង្វាន់សម្តេចធិបតី"
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងាររៀបចំការប្រកួត ឱ្យមានប្រសិទ្ធភាពនិងសម្រេចបានជោគជ័យ
- កៀរគរធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ
- ផ្សព្វផ្សាយយុទ្ធគុនខ្មែរបុរាណ នៅគ្រប់មជ្ឈដ្ឋាននិងទីកន្លែង
- រៀបចំរបាយការណ៍ ជូនសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- បំពេញកិច្ចការផ្សេងៗទៀតតាមការប្រគល់ជូនពីសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី។

**ប្រការ៥.-**

គណៈកម្មការចំពោះកិច្ចរៀបចំការប្រកួតកីឡាយុទ្ធគុនចម្រុះខ្មែរបុរាណ "ពានរង្វាន់សម្តេចធិបតី" មាន អនុគណៈកម្មការប្រតិបត្តិ និងបច្ចេកទេសរៀបចំការប្រកួត ជាចំណុះ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. ឯកឧត្តម **វ៉ាត់ ចំរើន** | ប្រធាន |
| ២. ឯកឧត្តម **ពេជ អន្ត** | អនុប្រធាន |
| ៣. បណ្ឌិត **សេខ ប៊ុនសុខ** | អនុប្រធានប្រចាំការ |
| ៤. ឯកឧត្តម **គង់ សូលីដា** | អនុប្រធាន |
| ៥. ឯកឧត្តម **គួច វែងស្រ៊ុន** | អនុប្រធាន |
| ៦. ឯកឧត្តម **ហួត ឃាងវេង** | អនុប្រធាន |
| ៧. ឯកឧត្តម **ម៉ៃ ស៊ីថន** | សមាជិក |
| ៨. ឯកឧត្តម **ផ្លូង ធឿន** | សមាជិក |
| ៩. ឯកឧត្តម **ស៊ឹម ឧុទ្ធា** | សមាជិក |
| ១០. ឯកឧត្តម **ប៊ុយ សុគ័ណ្ឋា** | សមាជិក |
| ១១. ឯកឧត្តម **ញ៉ាន សុខវិសាល** | សមាជិក |
| ១២. ឧត្តមសេនីយ៍ទោ **ខួច ឆាយ** | សមាជិក |
| ១៣. លោកស្រី **ម៉ី តាវី** | សមាជិក |
| ១៤. លោក **ឃូ ស៊ីណែត** | សមាជិក |
| ១៥. លោកស្រី **តៃ លីដា** | សមាជិក |
| ១៦. លោក **អ៊ូ តារា** | សមាជិក |
| ១៧. លោក **ជឹម ឆារ៉ា** | សមាជិក |
| ១៨. លោកស្រី **ថុន ស្រីដួង** | សមាជិក |
| ១៩. លោក **អន សុវឌ្ឍីយ៉ា** | សមាជិក |
| ២០. លោក **អន ចិន្ត្រាសំរិត** | សមាជិក |
| ២១. លោកស្រី **អេក សុតារ៉ា** | សមាជិក |
| ២២. លោក **យុត លី** | សមាជិក |
| ២៣. កញ្ញា **ហ៊ីន នីតា** | សមាជិក |
| ២៤. លោក **ម៉ក់ ចាន់អិរុណា** | សមាជិក |
| ២៥. កញ្ញា **ទ៉េត ឆានសិរីវេលក្ខ** | សមាជិក |
| ២៦. លោក **ថោង និស្ស័យទេព** | សមាជិក។ |

ការតែងតាំង និងផ្លាស់ប្តូរសមាសភាព អនុគណៈកម្មការប្រតិបត្តិ និងបច្ចេកទេសរៀបចំការប្រកួត ត្រូវធ្វើឡើងតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមការស្នើសុំរបស់ប្រធាន **គ.ច.យ.ខ.ពា.**។

អនុគណៈកម្មការប្រតិបត្តិ និងបច្ចេកទេសរៀបចំការប្រកួត អាចបង្កើតក្រុមការងារចំណុះតាមការចំបាច់។

ការបង្កើត និងតែងតាំងសមាសភាពក្រុមការងារចំណុះអនុគណៈកម្មការប្រតិបត្តិ និងបច្ចេកទេសរៀបចំ ការប្រកួត និងរបៀបរបបអនុវត្តការងារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ច.យ.ខ.ពា.**។



៩

**ប្រការ៦.-**

អនុគណៈកម្មការប្រតិបត្តិ និងបច្ចេកទេសរៀបចំការប្រកួត មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំកិច្ចការប្រចាំថ្ងៃរបស់ **គ.ច.ឃ.ខ.៣.**
- គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ របស់ **គ.ច.ឃ.ខ.៣.**
- រៀបចំបទបញ្ញាបច្ចេកទេសនិងបទបញ្ញាការប្រកួត
- រៀបចំការហាត់ហ្វឹកហ្វឺនរួមគ្នា ដើម្បីបង្កើតជំនាញប្រយុទ្ធនិងស្វែងយល់ពីបទបញ្ញាបច្ចេកទេស និងបទបញ្ញាការប្រកួត
- រៀបចំសិក្សាស្រាវជ្រាវ ស្វែងរកកីឡាករ កីឡាការិនី អ្នកហាត់គុន ឱ្យចូលរួមប្រកួតប្រយុទ្ធ និងប្រកួតសម្ដែងឱ្យបានច្រើនកុះករ គ្រប់ទម្រង់ និងគ្រប់យុទ្ធគុនខ្មែរបុរាណ
- រៀបចំបែបបទចុះឈ្មោះកីឡាករ កីឡាការិនីយុទ្ធគុនខ្មែរបុរាណចូលរួមការប្រកួត
- រៀបចំទីលានប្រកួត
- រៀបចំវគ្គបណ្ដុះបណ្ដាលអាជ្ញាកណ្ដាល-ចៅក្រម
- រៀបចំវិនិច្ឆ័យនិងលទ្ធផលការប្រកួត
- រៀបចំផ្សព្វផ្សាយនិងព័ត៌មាន
- រៀបចំសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ និងសុខាភិបាល
- ដោះស្រាយវិវាទបច្ចេកទេសក្នុងការប្រកួត
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាន **គ.ច.ឃ.ខ.៣.**។

**ប្រការ៧.-**

**គ.ច.ឃ.ខ.៣.** មានសិទ្ធិប្រើត្រារបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាសម្រាប់ដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

**ប្រការ៨.-**

**គ.ច.ឃ.ខ.៣.** មានប្រភពធនធានមកពីសប្បុរសជន ទីផ្សារ និងចលនទ្រព្យ ពីការផលិត មាតិកា ឬការផ្សព្វផ្សាយ និងពីប្រភពស្របច្បាប់ដទៃទៀត។

**ប្រការ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៦ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- សហព័ន្ធកីឡាជាតិពាក់ព័ន្ធ
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៩១ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការចាត់តាំងបន្ថែមអនុប្រធាន**

**ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចលេខ ២០៩ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ
- បានឃើញសេចក្តីសម្រេចលេខ ២១៥ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ
- បានឃើញសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៤ សណន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- យោងតាមសំណើរបស់ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ



៥

## សម្រេច

**ប្រការ១ .-**

ត្រូវបានចាត់តាំងបន្ថែមឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តពាក់ព័ន្ធ រដ្ឋបាលខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១១ សជណ

**សារាចរ**

**ស្ដីពី**

**ការអនុញ្ញាតឱ្យមន្ត្រីរាជការ បុគ្គលិក កម្មករ និយោជិត និងសិស្ស និស្សិត ឈប់សម្រាកក្នុងឱកាសចូលរួមអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤**

រាជរដ្ឋាភិបាលបានប្រកាសថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ជាថ្ងៃអបអរសាទរផ្លូវការនៃការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ដែលជាគម្រោងផ្តល់ផលប្រយោជន៍ដ៏មហាសាលដល់សង្គម-សេដ្ឋកិច្ចកម្ពុជា តាមរយៈសារាចរលេខ១០ សរ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤។ ដើម្បីឱ្យជនរួមជាតិខ្មែរគ្រប់រូបមានលទ្ធភាពចូលរួមអបអរសាទរ ប្រកបដោយបរិយាកាសអធិកអធម កុះករ ភ្លៀវភ្លា និងជាទីមោទនៈ នាឱកាសដ៏ថ្លៃថ្លានិងជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងស្មារតី **«គម្រោងរបស់ខ្មែរទាំងអស់គ្នា ដោយខ្មែរ និងដើម្បីខ្មែរគ្រប់រូប»** រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចតទៅ៖

១- អនុញ្ញាតឱ្យមន្ត្រីរាជការ បុគ្គលិក កម្មករ និយោជិត និងសិស្ស និស្សិត ឈប់សម្រាកចំនួន១(មួយ)ថ្ងៃ គឺនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ បន្ទាប់ពីការចូលរួមអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោជាផ្លូវការ នៅតាមក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈនិងឯកជន រោងចក្រ និងសហគ្រាសនីមួយៗ។

២- ការឈប់សម្រាកនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ របស់បុគ្គលិក និងកម្មករ និយោជិត ត្រូវទទួលបានប្រាក់ឈ្នួល។ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើសេចក្តីណែនាំដល់រោងចក្រ សហគ្រាស គ្រឹះស្ថាន អំពីការឈប់សម្រាកដោយមានប្រាក់ឈ្នួលនេះ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើសេចក្តីណែនាំដល់គ្រប់គ្រឹះស្ថានអប់រំសាធារណៈ និងឯកជនអំពីការឈប់សម្រាកនេះ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ សីហា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**
លេខ: ០១១/២៤.រកព.សលរ

# សេចក្តីសម្រេច
# ស្តីពី
# ការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ
# នៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

## រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣៣៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ ស្តីពីការផ្ទេរ ដំឡើង និងតែងតាំងមុខតំណែង ជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៤/៩០៥ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការតែងតាំងមុខដំណែង ជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១៨១ សសរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងរដ្ឋលេខាធិការប្រចាំការ
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន



អគារ Connexion(ជាន់ទី៣) វិថីកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
Connexion (3rd Floor), Koh Pich Street, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh
ទូរសព្ទលេខ : (+៨៥៥) ១០ ២៥៨ ៩៦៧ / (+៨៥៥) ១១ ៧៥២ ៧៩៣
Tel: (+855) 10 258 967 / (+855) 11 752 793

## សម្រេច

**ប្រការ១ .-**

ត្រូវបានបែងចែកភារកិច្ចជូនរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដូចខាងក្រោម៖

**ក- រដ្ឋមន្ត្រី**

ឯកឧត្តម **ឡាំ ជា** ទទួលបន្ទុកដឹកនាំការងាររួមរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

**ខ- រដ្ឋលេខាធិការ**

១- ឯកឧត្តម **អ៊ិត សុគ្គា** រដ្ឋលេខាធិការប្រចាំការ បំពេញភារកិច្ចតាមអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ និងទទួលជួយរដ្ឋមន្ត្រីលើការងារ ដូចខាងក្រោម៖
- ការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-ថៃ និង
- ការងារអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន។

២- ឯកឧត្តម **ស៊ុម សុខម្ភុ** ទទួលជួយរដ្ឋមន្ត្រីលើការងារ ដូចខាងក្រោម៖
- ការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម
- ការងារទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម
- ការងារធនធានមនុស្ស
- ការងារគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រំដែន និង
- ការងារអភិវឌ្ឍព្រំដែន។

៣- ឯកឧត្តម **ង ខុន្ធារី** ទទួលជួយរដ្ឋមន្ត្រីលើការងារ ដូចខាងក្រោម៖
- ការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-ឡាវ
- ការងារហិរញ្ញវត្ថុ
- ការងារតាមដានព័ត៌មានជាតិនិងអន្តរជាតិ
- ការងារព័ត៌មានវិទ្យា និង
- ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

៤- ឯកឧត្តម **មាស បូរ៉ា** ទទួលជួយរដ្ឋមន្ត្រីលើការងារ ដូចខាងក្រោម៖
- ការងារកំណត់ព្រំដែនសមុទ្រកម្ពុជា-វៀតណាម និងកម្ពុជា-ថៃ
- ការងារស្រាវជ្រាវនិងវិភាគជាយុទ្ធសាស្ត្រ និង
- ការងារបណ្តុះបណ្តាលនិងផ្សព្វផ្សាយ។

៥- ឯកឧត្តម **សៀន សុវណ្ណារ៉ា** ទទួលជួយរដ្ឋមន្ត្រីលើការងារ ដូចខាងក្រោម៖
- ការងារត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែន
- ការងារនាយកដ្ឋានកិច្ចការទូទៅ និង
- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។

**គ- អនុរដ្ឋលេខាធិការ**

១- ឯកឧត្តម **ឡាយ សៀងលី** ទទួលជួយឯកឧត្តម **អ៊ិត សុត្ថា** លើការងារ ដូចខាងក្រោម៖
- ការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-ថៃ និង
- ការងារអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន។

២- ឯកឧត្តម **សោ សុន្ទរ៍ធារី** ទទួលជួយឯកឧត្តម **ស៊ុំ សុខម្ហ** លើការងារ ដូចខាងក្រោម៖
- ការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម និង
- ការងារគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រំដែន។

៣- ឯកឧត្តម **សាន់ វ៉ាដា** ទទួលជួយឯកឧត្តម **ស៊ុំ សុខម្ហ** លើការងារ ដូចខាងក្រោម៖
- ការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម
- ការងារទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម និង
- ការងារអភិវឌ្ឍព្រំដែន។

៤- ឯកឧត្តម **ផល ពិសាល** ទទួលជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី។

៥- ឯកឧត្តម **អាន សុវឌ្ឍនា** ទទួលជួយឯកឧត្តម **ឯ ឌុឌ្ឍី** លើការងារ ដូចខាងក្រោម៖
- លើការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-ឡាវ
- ការងារហិរញ្ញវត្ថុ
- ការងារតាមដានព័ត៌មានជាតិនិងអន្តរជាតិ និង
- ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

៦- ឯកឧត្តម **ពៅ ករុណា** ទទួលជួយ៖
- **ឯកឧត្តម រដ្ឋមន្ត្រី** លើការងាររដ្ឋបាលនិងពិធីការ ការងារសម្របសម្រួលនិងទំនាក់ទំនងការងារទូទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន និងសម្របសម្រួលការងារចាត់តាំងក្រុមការងារព្រំដែន
- ឯកឧត្តម **អ៊ិត សុត្ថា** លើការងារអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន
- ឯកឧត្តម **ស៊ុំ សុខម្ហ** លើការងារធនធានមនុស្ស។

៧- ឯកឧត្តម **ជា ប៊ូរ៉ា** ទទួលជួយឯកឧត្តម **មាស ប៊ូរ៉ា** លើការងារ ដូចខាងក្រោម៖
- ការងារបណ្តុះបណ្តាលនិងផ្សព្វផ្សាយ និង
- ការងារកំណត់ព្រំដែនសមុទ្រកម្ពុជា-វៀតណាម។

៨- ឯកឧត្តម **ឌី ដាម៉ង់** ទទួលជួយឯកឧត្តម **មាស ប៊ូរ៉ា** លើការងារ ដូចខាងក្រោម៖
- ការងារស្រាវជ្រាវនិងវិភាគជាយុទ្ធសាស្ត្រ និង
- ការងារកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ។

៩- ឯកឧត្តម **អ៊ិត ដារ៉ា** ទទួលជួយឯកឧត្តម **ឯ ឌុឌ្ឍី** លើការងារព័ត៌មានវិទ្យា។

១០- ឯកឧត្តម **ឃ្លោក រតន្បី** ទទួលជួយឯកឧត្តម **សៀន សុវណ្ណរ៉ា** លើការងារក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។

១១- ឯកឧត្តម **យ៉ន អ៊ីរិន** ទទួលជួយឯកឧត្តម **សៀន សុវណ្ណារា** លើការងារ ដូចខាងក្រោម៖

- ការងារត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែន និង
- ការងារនាយកដ្ឋានកិច្ចការទូទៅ។

**ប្រការ២ .-**

ក្រៅពីភារកិច្ចដូចមានចែងខាងលើ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការគ្រប់រូបត្រូវបំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងអង្គភាពក្រោមឱវាទរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៥ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ឡាំ ជា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

STATE SECRETARIAT OF BORDER AFFAIRS

**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**
លេខ: ០១២/២៤.អកស.សាវ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល លេខ 2953
ថ្ងៃទី 23 ខែ 08 ឆ្នាំ 2024
ម៉ោង 8h40

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអប់រំ និងផ្សព្វផ្សាយ អំពីកិច្ចការព្រំដែន កម្ពុជា-ថៃ កម្ពុជា-ឡាវ និងកម្ពុជា-វៀតណាម

## រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារអប់រំ និងផ្សព្វផ្សាយអំពីកិច្ចការព្រំដែន កម្ពុជា-ថៃ កម្ពុជា-ឡាវ និងកម្ពុជា-វៀតណាម ដែលរួមមាន ដូចខាងក្រោម៖

**ក- ក្រុមការងារគ្រប់គ្រងកម្មវិធីអប់រំ និងផ្សព្វផ្សាយ**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឡាំ ជា** | រដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **អ៊ិត សុគ្គា** | រដ្ឋលេខាធិការប្រចាំការ | អនុប្រធាន |
| ៣- ឯកឧត្តម | **ស៊ុំ សុខម្ហ** | រដ្ឋលេខាធិការ | អនុប្រធានប្រចាំការ |
| ៤- ឯកឧត្តម | **៦ ឌុឌ្ឍី** | រដ្ឋលេខាធិការ | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៥- | ឯកឧត្តម | **មាស ប្ញូរ៉ា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៦- | ឯកឧត្តម | **សៀន សុវណ្ណារា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៧- | ឯកឧត្តម | **ឡាយ សៀងលី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨- | ឯកឧត្តម | **សោ សុន្ទរ៍ធារី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩- | ឯកឧត្តម | **សាន់ រ៉ាដា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១០- | ឯកឧត្តម | **ផល ពិសាល** | អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី | សមាជិក |
| ១១- | ឯកឧត្តម | **អាន សុវឌ្ឍនា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១២- | ឯកឧត្តម | **ពៅ ករុណា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៣- | ឯកឧត្តម | **ជា ប្ញូរ៉ា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៤- | ឯកឧត្តម | **ឌី ដាម៉ង់** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៥- | ឯកឧត្តម | **ឃុំ ប៉ុណ្ណារ័ត្ន** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |
| ១៦- | លោក | **ខន ដានិត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ១៧- | លោក | **ហោង សេរីម៉េង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ១៨- | លោក | **ស្រ៊ី ប្ញូរ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |
| ១៩- | លោក | **ឃុន ចំរើន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន | សមាជិក |
| ២០- | លោកស្រី | **ច័ន្ទ សោភ័ណា** | ប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារផែនទីនិងទិន្នន័យព្រំដែន | សមាជិក |
| ២១- | លោកស្រី | **ទេព ផារ៉េត** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ២២- | លោក | **ប៉ែន ជីវ័ន្តនី** | ប្រធាននាយកដ្ឋានធនធានមនុស្សនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |

**ខ- ក្រុមការងាររៀបចំឯកសារសម្រាប់អប់រំ និងផ្សព្វផ្សាយ**

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **មាស ប្ញូរ៉ា** | រដ្ឋលេខាធិការ | ប្រធាន |
| ២- | ឯកឧត្តម | **ឡាយ សៀងលី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- | ឯកឧត្តម | **សាន់ រ៉ាដា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤- | ឯកឧត្តម | **ឌី ដាម៉ង់** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៥- | ឯកឧត្តម | **ឃុំ ប៉ុណ្ណារ័ត្ន** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | អនុប្រធាន |
| ៦- | លោក | **ស្រ៊ី ប្ញូរ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | អនុប្រធាន |
| ៧- | លោក | **មឿន រិទ្ធី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |
| ៨- | លោក | **ឃុន ចំរើន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន | សមាជិក |

| | | | |
|---|---|---|---|
| ៩- លោក | **ហាស់ ផល្លារិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយ និងអភិវឌ្ឍន៍តំបន់ព្រំដែន | សមាជិក |
| ១០- លោកស្រី | **ច័ន្ទ សោភ័ណា** | ប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារផែនទី និងទិន្នន័យព្រំដែន | សមាជិក |
| ១១- លោក | **លី សុខសុធា** | ប្រធាននាយកដ្ឋានវាស់វែង នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |
| ១២- លោក | **ម៉ក់ ពិសិដ្ឋ** | ប្រធាននាយកដ្ឋានប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ផែនទី និងសំណង់ នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |
| ១៣- លោក | **ហុង អ៊ីនូអុង** | ប្រធាននាយកដ្ឋានដោះស្រាយបាតុភាពតាមបណ្ដោយព្រំដែន នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |
| ១៤- លោក | **ណែម មូរា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ព្រំដែន នៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន | សមាជិក |
| ១៥- លោក | **ព្រំសឿន វឌ្ឍនៈ** | អនុប្រធាននាយកដ្ឋានវាស់វែង នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |
| ១៦- លោក | **នេត សុធារៈ** | អនុប្រធាននាយកដ្ឋានវាស់វែង នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |
| ១៧- លោក | **ភាំង សេងលី** | អនុប្រធាននាយកដ្ឋានប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ផែនទី និងសំណង់ នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |

**គ- ក្រុមលេខាធិការ**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ពៅ ករុណា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម | **ជា មូរ៉ា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- លោក | **ស្រ៊ី មូរ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន | អនុប្រធាន |
| ៤- លោក | **ខន ដានិត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- លោក | **ហេង សេរីម៉េង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៦- លោកស្រី | **ទេព ផារ៉េត** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃអគ្គនាយដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៧- លោក | **ប៉ែន ជីវ័ន្តនរី** | ប្រធាននាយកដ្ឋានធនធានមនុស្ស នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៨- លោកស្រី | **ឈាង ម៉ិនតូណា** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម នៃអគ្គនាយដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៩- លោក | **យុង ហុងលិ** | ជំនួយការរដ្ឋលេខាធិការប្រចាំការ | សមាជិក |
| ១០- លោកស្រី | **យិន ភុមុទគន្ធា** | ជំនួយការរដ្ឋលេខាធិការ | សមាជិក |

| | | | |
|---|---|---|---|
| ១១- លោក | **ម៉ិច សារ៉ាត្រា** | ជំនួយការរដ្ឋលេខាធិការ | សមាជិក |
| ១២- លោក | **សាន វិច្ឆរ៉ា** | ជំនួយការរដ្ឋលេខាធិការ | សមាជិក |
| ១៣- លោក | **ទីន សុខលីម** | មន្ត្រីនៃនាយកដ្ឋានធនធានមនុស្ស | សមាជិក |
| ១៤- លោក | **តាំង នីរ៉ាក់** | មន្ត្រីនៃវិទ្យាស្ថានជាតិកិច្ចការព្រំដែន | លេខាកត់ត្រា |
| ១៥- លោក | **អ៊ុនចាន់តារ៉ាវុធ** | មន្ត្រីនៃវិទ្យាស្ថានជាតិកិច្ចការព្រំដែន | លេខាកត់ត្រា |

**ឃ- ក្រុមការងារបកប្រែ**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ផល ពិសាល** | អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **អាន សុវឌ្ឍនា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- លោក | **ភឹម វឌ្ឍនៈ** | នាយករងខុទ្ទកាល័យរដ្ឋមន្ត្រី | អនុប្រធាន |
| ៤- លោកស្រី | **យិន កុមុទគន្ធា** | ជំនួយការរដ្ឋលេខាធិការ | សមាជិក |
| ៥- លោកស្រី | **គង់ សុវណ្ណារ៉េត** | ជំនួយការអនុរដ្ឋលេខាធិការ | សមាជិក |
| ៦- លោក | **ព្រេង តារុន** | មន្ត្រីនៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម | សមាជិក |
| ៧- លោក | **ម៉ាត់ លីសៃយ៉ា** | មន្ត្រីនៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម | សមាជិក |

**ប្រការ២ .-**

ក្រុមការងារគ្រប់គ្រងកម្មវិធីអប់រំ និងផ្សព្វផ្សាយ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- កំណត់ចក្ខុវិស័យនិងទិសដៅអាទិភាពសម្រាប់ការអប់រំ និងផ្សព្វផ្សាយ
- រៀបចំផែនការកម្មវិធីអប់រំ និងផ្សព្វផ្សាយអំពីកិច្ចការព្រំដែន ទាំងទិដ្ឋភាពច្បាប់ និងបច្ចេកទេស
- កំណត់សិក្ខាកាមគោលដៅ ទីកន្លែងអប់រំ ផ្សព្វផ្សាយ និងគោលដៅទស្សនកិច្ចសិក្សា
- ដឹកនាំសម្របសម្រួល និងតម្រង់ទិសការងារបម្រើឱ្យគោលដៅអប់រំ និងផ្សព្វផ្សាយ
- កំណត់គោលការណ៍ណែនាំស្ដីពីការប្រើប្រាស់ព័ត៌មាននិងឯកសារអប់រំ និងផ្សព្វផ្សាយ
- ចាត់តាំងគ្រូឧទ្ទេស និងគ្រូជំនួយ ដើម្បីអប់រំ និងផ្សព្វផ្សាយអំពីកិច្ចការព្រំដែន ទាំងទិដ្ឋភាពច្បាប់ និងបច្ចេកទេស
- ពិនិត្យនិងសម្រេចលើសំណើរបស់ក្រុមការងាររៀបចំឯកសារអប់រំ និងផ្សព្វផ្សាយ ក្រុមលេខាធិការ និងក្រុមការងារបកប្រែ
- វាយតម្លៃកម្មវិធីនិងលទ្ធផលអប់រំ ផ្សព្វផ្សាយ និងផ្ដល់អនុសាសន៍កែលម្អ
- រៀបចំសលាកបត្រវាយតម្លៃគ្រូ និងលទ្ធផលនៃការអប់រំ និងផ្សព្វផ្សាយ
- អនុវត្តភារកិច្ចផ្សេងទៀត តាមប្រគល់ជូនពីរដ្ឋមន្ត្រី។

**ប្រការ៣ .-**

ក្រុមការងាររៀបចំឯកសារអប់រំ និងផ្សព្វផ្សាយ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំ ចងក្រងឯកសារសម្រាប់អប់រំ និងផ្សព្វផ្សាយអំពីកិច្ចការព្រំដែន ទាំងទិដ្ឋភាពច្បាប់ និងបច្ចេកទេស
- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិពាក់ព័ន្ធ សម្រាប់បម្រើឱ្យការងារអប់រំ និងផ្សព្វផ្សាយ
- អនុវត្តភារកិច្ចផ្សេងទៀត តាមប្រគល់ជូនពីប្រធានក្រុមការងារគ្រប់គ្រងកម្មវិធីអប់រំ និងផ្សព្វផ្សាយ។

**ប្រការ៤ .-**

ក្រុមលេខាធិការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំសេចក្ដីព្រាងផែនការអប់រំ និងផ្សព្វផ្សាយ
- សម្របសម្រួល និងរៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយ
- រៀបចំសេចក្ដីព្រាងគម្រោងចំណាយសម្រាប់កម្មវិធីអប់រំ និងផ្សព្វផ្សាយ
- រៀបចំបោះពុម្ពឯកសារដែលរៀបចំដោយក្រុមការងាររៀបចំឯកសារអប់រំ និងផ្សព្វផ្សាយ ក្រោយពីទទួលបានការឯកភាពពីប្រធានក្រុមការងារគ្រប់គ្រងកម្មវិធីអប់រំ និងផ្សព្វផ្សាយ
- រៀបចំមធ្យោបាយដឹកជញ្ជូន សម្ភារៈ និងបរិក្ខារដើម្បីគាំទ្រដល់កម្មវិធីអប់រំ និងផ្សព្វផ្សាយ
- អនុវត្តភារកិច្ចផ្សេងទៀត តាមប្រគល់ជូនពីប្រធានក្រុមការងារគ្រប់គ្រងកម្មវិធីអប់រំ និងផ្សព្វផ្សាយ។

**ប្រការ៥ .-**

ក្រុមការងារបកប្រែ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- បកប្រែកិច្ចព្រមព្រៀង សន្ធិសញ្ញាអន្តរជាតិ អនុសញ្ញាអន្តរជាតិ ពិធីសារ កំណត់ហេតុ លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ និងឯកសារពាក់ព័ន្ធ
- សហការសម្របសម្រួលជាមួយក្រុមការងាររៀបចំឯកសារអប់រំ និងផ្សព្វផ្សាយ និងក្រុមលេខាធិការ ដើម្បីរៀបចំចងក្រងឯកសារសម្រាប់អប់រំ និងផ្សព្វផ្សាយ ព្រមទាំងសម្របសម្រួលការងារស្រាវជ្រាវ និងចងក្រងឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់បម្រើឱ្យការងារអប់រំ និងផ្សព្វផ្សាយ
- អនុវត្តភារកិច្ចផ្សេងទៀត តាមប្រគល់ជូនពីប្រធានក្រុមការងារគ្រប់គ្រងកម្មវិធីអប់រំ និងផ្សព្វផ្សាយ។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន នាយកវិទ្យាស្ថានជាតិកិច្ចការព្រំដែន ប្រធានគ្រប់អង្គភាពក្រោមឱវាទរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ២ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ឡាំ ជា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤២១៧ សហវ.ប្រក.រអក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតវិក្កយបត្រទេយ្យចំណូលសម្រាប់ឆ្នាំ២០២៤
## នៅក្រសួងពាណិជ្ជកម្ម

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៩២៦ សហវ.ប្រក.អថ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតរដ្ឋទេយ្យចំណូលនៅក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ បញ្ជីរាយប្រភេទចំណូលដែលត្រូវបង្កើតរដ្ឋទេយ្យចំណូលឆ្នាំ២០២៤ មានដូចខាងក្រោម៖

| | |
|---|---|
| ១. អនុគណនី ៧៣០០៨ ផលទុនផ្សេងៗ | ៤ ៨០០ ០០០ ០០០ រៀល |
| ២. អនុគណនី ៧៣០១២ លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | ៨៩០ ០០០ ០០០ រៀល |
| ៣. អនុគណនី ៧៣០២៣ ផលពីការបង្កើតសហគ្រាស | ១២ ៣០០ ០០០ ០០០ រៀល |
| ៤. អនុគណនី ៧៣០៤៨ ផលពីសេវាផ្សេងៗទៀត | ២ ៧០០ ០០០ ០០០ រៀល |
| ៥. អនុគណនី ៧៣០៦៥ ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | ៤០ ០០០ ០០០ រៀល |
| ៦. អនុគណនី ៧៣០៦៧ កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ២៦ ៥០០ ០០០ ០០០ រៀល |
| ៧. អនុគណនី ៧៣០៨៧ ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | ២ ៥០០ ០០០ ០០០ រៀល |
| ៨. អនុគណនី ៧៤០១២ ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យប្រាក់ | ២ ៤០០ ០០០ ០០០ រៀល |
| សរុបទឹកប្រាក់ | ៥២ ១៣០ ០០០ ០០០ រៀល |

**ប្រការ២.-**

ចំនួនទឹកប្រាក់អតិបរមាដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន ២ ០០០ ០០០រៀល( ពីរលានរៀលគត់ )។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គាធិការ ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃពុធ ៥កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៩២៩ សហវ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតក្រុមការងារតិតគូរ និងរៀបចំយន្តការអភិបាលកិច្ចមន្ទីរពេទ្យគន្ធបុប្ផា រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៣៨២ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីមូលនិធិគន្ធបុប្ផាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត ក្រុមការងារគិតគូរ និងរៀបចំយន្តការអភិបាលកិច្ចមន្ទីរពេទ្យគន្ធបុប្ផា ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | លោកជំទាវ **ម៉ែន សុមនា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តមវេជ្ជបណ្ឌិត **យូ ពិសី** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៣. | ឯកឧត្តមបណ្ឌិត **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | ឯកឧត្តម **ហាច រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. | ឯកឧត្តមវេជ្ជបណ្ឌិត **ហុក គីមចេង** | អគ្គនាយកបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល | សមាជិក |
| ៦. | ឯកឧត្តម **ជិន ទិសាល** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងសុខាភិបាល | សមាជិក |
| ៧ | ឯកឧត្តម **តន្ត្រី សម្បូរណ៍** | តំណាងមូលនិធិគន្ធបុប្ផាកម្ពុជា | សមាជិក |
| ៨ | លោកសាស្ត្រាចារ្យ **គី សន់នី** | ប្រធានមន្ទីរពេទ្យគន្ធបុប្ផាភ្នំពេញ | សមាជិក |
| ៩. | លោកសាស្ត្រាចារ្យ **យ៉ៃ ចន្ទនា** | ប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ (គន្ធបុប្ផាសៀមរាប) | សមាជិក |
| ១០ | លោកស្រីវេជ្ជបណ្ឌិត **កើត ពេជ្រចិន្តា** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក និងជាលេខាធិការ។ |

**ប្រការ ២.-**

ក្រុមការងារនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- គិតគូរ និងកំណត់ចក្ខុវិស័យ និងក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីតម្រង់ទិស និងជំរុញការអភិវឌ្ឍមន្ទីរពេទ្យគន្ធបុប្ផា ជាមជ្ឈមណ្ឌលឧត្តមភាព និងជាមន្ទីរពេទ្យគំរូ
- រៀបចំបង្កើតនីតិវិធី និងយន្តការនៃកិច្ចសហប្រតិបត្តិការក្នុងការផ្តល់ហិរញ្ញប្បទានរបស់រដ្ឋ តាមរយៈមូលនិធិគន្ធបុប្ផាកម្ពុជា ស្របតាមតម្រូវការរបស់មន្ទីរពេទ្យគន្ធបុប្ផា ដើម្បីធានានិរន្តរភាពនៃកិច្ចដំណើរការ
- សហការជាមួយតំណាងមូលនិធិគន្ធបុប្ផាស្វីស និងថ្នាក់ដឹកនាំមន្ទីរពេទ្យគន្ធបុប្ផា ដើម្បីតាមដានលើទិដ្ឋភាពហិរញ្ញវត្ថុ និង
- អនុវត្តភារកិច្ចដទៃទៀត តាមការណែនាំរបស់ប្រធានក្រុមការងារ។

**ប្រការ ៣.-**

ប្រធានក្រុមការងារគិតគូរ និងរៀបចំយន្តការអភិបាលកិច្ចមន្ទីរពេទ្យគន្ធបុប្ផាអាចអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដែលមិនមែនជាសមាជិកក្រុមការងារឱ្យចូលរួមប្រជុំ ដើម្បីពិនិត្យ និងផ្តល់យោបល់ តែពុំមានសិទ្ធិសម្រេចឡើយ។

**ប្រការ ៤.-**

ប្រកាសអន្តរក្រសួងលេខ៤០៣ សហវ. ប្រក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារគិតគូរ និងរៀបចំយន្តការអភិបាលកិច្ចមន្ទីរពេទ្យគន្ធបុប្ផារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងមូលនិធិគន្ធបុប្ផាកម្ពុជា ព្រមទាំងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៧កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**សាស្ត្រាចារ្យ ឈាន រ៉ា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៦៩......សហវ.គស.គស.គស.

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងសិក្សា និងរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ**
**គោលនយោបាយវិស័យសំណង់-អចលនទ្រព្យកម្ពុជារយៈពេលវែង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រង អាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- បានឃើញប្រកាសលេខ ០៨៩ សហវ.ប្រក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ ស្ដីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញប្រកាសលេខ ០៦៤ អ.ស.ហ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីអាជីវកម្មផ្ដល់សេវាកម្មអចលនវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីសិក្សា និងរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រគោលនយោបាយគ្រប់គ្រងការអភិវឌ្ឍវិស័យសំណង់-អចលនទ្រព្យកម្ពុជាក្នុងរយៈពេលវែង ដែលសរសេរអក្សរកាត់ថា (**ក.ប.ស.ស**) ដោយមានអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**គ.ស.ហ**) ជាស្ថាប័នសម្របសម្រួល និង ដឹកនាំ។

**ប្រការ២._**

ក្រុមការងារនេះ មានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| - ឯកឧត្តមបណ្ឌិត **ផាន់ ផល្លា** | រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃ គ.ស.ហ | ប្រធាន |
| - ឯកឧត្តម **គង់ ទិបុល** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៃ ក.ស.ហ.វ | អនុប្រធាន |
| - ឯកឧត្តម **រស់ សាលីន** | រដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| - ឯកឧត្តម **អ៊ុច លុយណា** | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនៃ ក.ស.ហ.វ និងជាអគ្គលេខាធិការរងនៃ គ.ស.ហ | អនុប្រធានប្រចាំការ |
| - ឯកឧត្តម **ឱម ម៉ាត់ធារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន នៃ ក.ស.ហ.វ | សមាជិក |
| - ឯកឧត្តម **អ៊ុន មាត្រា** | អគ្គនាយករងនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ | សមាជិក |
| - ឯកឧត្តម **កែន សម្បត្តិ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារនៃ ក.ស.ហ.វ | សមាជិក |
| - លោក **ឡាយ សុខហេង** | អគ្គនាយករងនៃធនាគារជាតិកម្ពុជា | សមាជិក |
| - លោក **អ៊ុច ទិសិដ្ឋ** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានប្រជាជន និងអភិវឌ្ឍន៍ នៃក្រសួងផែនការ | សមាជិក |

| | | |
|---|---|---|
| - លោក **អេង រតនា** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ នៃ ក.ស.ហ.វ | សមាជិក |
| - លោក **ម៉ក់ ខិចិត្រសក្កដា** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានគោលនយោបាយ នៃ ក.ស.ហ.វ | សមាជិក |
| - លោកស្រី **តាន់ ឡានីន** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃ ក.ស.ហ.វ | សមាជិក |
| - លោក **លន់ សំអុល** | ប្រធាននាយកដ្ឋាននៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| - លោក **ជីវ ស៊ីវផេង** | ប្រធាននាយកដ្ឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - លោក **ម៉ៅ ពៅ** | ប្រធាននាយកដ្ឋាននៃនិយ័តករអាជីវកម្ម អចលនវត្ថុ និងបញ្ចាំ | សមាជិក |
| - លោក **ខាំ ឧត្តម** | ប្រធានការិយាល័យនៃអគ្គលេខាធិការដ្ឋាន ប្រជាជននិងអភិវឌ្ឍន៍ នៃក្រសួងផែនការ | សមាជិក |
| - លោក **ហេង សាលវ៉ាស៊ី** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃ ក.ស.ហ.វ | សមាជិក |
| - លោក **ឯក ច័ន្ទបូរ៉ា** | អនុប្រធានការិយាល័យនៃនិយ័តករអាជីវកម្ម និងអចលនវត្ថុ និងបញ្ចាំ | សមាជិក |
| - លោក **ម៉ៅ សុណារិទ្ធ** | ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ | សមាជិក |
| - លោក **ស៊ាន មនោរិទ្ធ** | មន្ត្រីនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក.ស.ហ.វ | សមាជិក។ |

**ប្រការ៣.**_

ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ដឹកនាំ សម្របសម្រួល និងរៀបចំក្របខ័ណ្ឌគោលនយោបាយគ្រប់គ្រងការអភិវឌ្ឍវិស័យសំណង់-អចលនទ្រព្យកម្ពុជាក្នុងរយៈពេលវែង
- សិក្សា និងពិនិត្យលើការអនុវត្ត មុខងារ និងតួនាទីជាក់ស្តែងរបស់ក្រសួងស្ថាប័នពាក់ព័ន្ធលើការគ្រប់គ្រងការអភិវឌ្ឍវិស័យសំណង់-អចលនទ្រព្យកម្ពុជា
- សិក្សា ពិនិត្យ និងបង្កើតយន្តការរួមលើការគ្រប់គ្រង, អនុវត្ត, ដោះស្រាយ, ត្រួតពិនិត្យ, តាមដាន និងវាយតម្លៃលើការអភិវឌ្ឍវិស័យសំណង់-អចលនទ្រព្យកម្ពុជា
- សិក្សា និងរៀបចំវិធានការរយៈពេលខ្លី មធ្យម និងវែង (ផ្នែកសារពើពន្ធ, ផ្នែករូបិយវត្ថុ និងផ្នែករដ្ឋបាល) សម្រាប់គ្រប់គ្រងការអភិវឌ្ឍវិស័យសំណង់-អចលនទ្រព្យកម្ពុជា
- ពិនិត្យ និងសិក្សាស្រាវជ្រាវឧត្តមានុវត្តន៍អន្តរជាតិនូវបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធសំខាន់ៗ
- សហការចូលរួមផ្តល់ឯកសារ ព័ត៌មាន ជាតុចូល សម្រាប់ការសិក្សាស្រាវជ្រាវ
- រៀបចំកិច្ចប្រជុំ សិក្ខាសាលាពិគ្រោះយោបល់ និង ទស្សនកិច្ចសិក្សាក្នុងនិងក្រៅប្រទេស ជាមួយភាគីពាក់ព័ន្ធដើម្បីប្រមូលធាតុចូលចាំបាច់ឱ្យបានគ្រប់ជ្រុងជ្រោយ
- រៀបចំរបាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹងការសិក្សា ជូន **គ.ស.ហ** និង
- បំពេញតួនាទី និងភារកិច្ចផ្សេងទៀត តាមការណែនាំរបស់ប្រធានក្រុមការងារ និង **គ.ស.ហ** ។

**ប្រការ៤.**_

ក្នុងករណីដែលប្រធានក្រុមការងារអវត្តមាន ឬមានករណីចាំបាច់, ប្រធានក្រុមការងារអាចផ្ទេរសិទ្ធិជូនអនុប្រធានណាមួយ ដើម្បីដឹកនាំកិច្ចប្រជុំ ។ សមាជិកក្រុមការងារត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធានក្រុមការងារ ឬអនុប្រធានណាមួយ ក្នុងករណីដែលប្រធាន អវត្តមាន ឬមានករណីចាំបាច់ ។

**ប្រការ៥.**_

ក្រុមការងារនេះ មានសិទ្ធិអញ្ជើញក្រសួងស្ថាប័ន, វិស័យឯកជន, ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀត ចូលរួមប្រជុំ តាមការចាំបាច់ ។

ក្រុមការងារនេះ អាចស្នើសុំថវិកា និងធនធាន ដែលចាំបាច់ ក្នុងដំណើរការនៃការបំពេញភារកិច្ច ។

**ប្រការ៦.**_

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសមាសភាពដូចមានចែងក្នុងប្រការ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១០កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី